ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ.១០៩០..............សហវ.ប្រក

# ប្រកាស

## ស្តីពី

## វិធាន និងនីតិវិធីសម្រាប់អនុវត្តភាតព្វកិច្ច

## សារពើពន្ធចំពោះសហគ្រាសប្រកបអាជីវកម្មល្បែងពាណិជ្ជកម្ម

## ឧបនាយករដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣១ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.- គោលបំណង**

ប្រកាសនេះ មានគោលបំណងកំណត់នូវវិធាន និងនីតិវិធីសម្រាប់អនុវត្តកាតព្វកិច្ចសារពើពន្ធចំពោះសហគ្រាសប្រកបអាជីវកម្មល្បែងពាណិជ្ជកម្ម ដើម្បីធានាបាននូវប្រសិទ្ធភាពក្នុងការគ្រប់គ្រងប្រមូលពន្ធ-អាករលើអាជីវកម្មល្បែងពាណិជ្ជកម្មគ្រប់ប្រភេទ។

**ប្រការ២.- វិសាលភាព**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ដែលប្រកបអាជីវកម្មល្បែងពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣.- និយមន័យ**

សម្រាប់គោលដៅនៃប្រកាសនេះ÷

១- ពាក្យ **"ល្បែងពាណិជ្ជកម្ម"** សំដៅដល់ល្បែងកាស៊ីណូ ល្បែងភ្នាល់ ល្បែងផ្សងសំណាង និង/ឬល្បែងពាណិជ្ជកម្មដទៃទៀត ដែលត្រូវបានធ្វើប្រតិបត្តិការ ដើម្បីគោលបំណងបង្កើតប្រាក់ចំណេញ ឬដើម្បីគោលបំណងពាណិជ្ជកម្ម។

២- ពាក្យ **"ល្បែងកាស៊ីណូ"** សំដៅដល់ល្បែងពាណិជ្ជកម្មដែលត្រូវបានដំណើរការនៅក្នុងកាស៊ីណូរួមមាន ផ្ទុកឃើ ប្លេកជេក បាការ៉ាត រ៉ូឡែត ស្លុតម៉ាស៊ីន និង/ឬល្បែងផ្សេងទៀត ដោយប្រើសន្លឹកបៀ គ្រាប់ឡុកឡាក់ ឧបករណ៍មេកានិក អេឡិចត្រូមេកានិក ឬអេឡិចត្រូនិក និង/ឬឧបករណ៍ និង/ឬកម្មវិធីល្បែងផ្សេងទៀត។

៣- ពាក្យ **"ល្បែងភ្នាល់"** សំដៅដល់ល្បែងពាណិជ្ជកម្មដែលផ្អែកលើការទស្សន៍ទាយលទ្ធផលនៃការប្រណាំង ការប្រកួត ឬព្រឹត្តិការណ៍ឥតព្រាងទុកណាមួយ។

៤- ពាក្យ **"ល្បែងផ្សងសំណាង"** សំដៅដល់ល្បែងពាណិជ្ជកម្មដែលដំណើរការនៅក្រៅកាស៊ីណូដោយផ្អែកទៅលើសំណាងសុទ្ធសាធ ឬលើសំណាងមួយផ្នែក និងជំនាញរបស់ភ្ញៀវល្បែងមួយផ្នែក ដូចជា ល្បែងឆ្នោត ឡូតូ និង/ឬល្បែងផ្សងសំណាងផ្សេងទៀត។

៥- ពាក្យ **"ចំណូលសរុបពីល្បែង"** សំដៅដល់ផលសរុបនៃ ចំណូលដុលដែលបានទទួល ឬត្រូវទទួលពីសកម្មភាពល្បែងពាណិជ្ជកម្មគ្រប់ប្រភេទ ដកចេញនូវប្រាក់ឈ្នះទាំងឡាយណាដែលបានទូទាត់ដល់ភ្ញៀវល្បែង។

**ប្រការ៤.- ភាតព្វកិច្ចចុះបញ្ជីពន្ធដារ**

បុគ្គលទាំងឡាយណាដែលប្រកបអាជីវកម្មល្បែងពាណិជ្ជកម្ម ត្រូវចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធក្នុងអំឡុងពេល ១៥ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយបុគ្គលនោះចាប់ផ្តើមធ្វើសកម្មភាពសេដ្ឋកិច្ច ឬក្រោយពីពេលទទួលបានលិខិតបញ្ជាក់ការចុះបញ្ជី ឬលិខិតអនុញ្ញាតចេញដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ។ រដ្ឋបាលសារពើពន្ធមានសិទ្ធិចុះបញ្ជីពន្ធដារជាឯកតោភាគី ក្នុងករណីដែលបុគ្គលនោះពុំបានមកចុះបញ្ជី ឬមិនបានមកចុះបញ្ជីតាមការអញ្ជើញរបស់រដ្ឋបាលសារពើពន្ធ ដោយផ្អែកលើព័ត៌មាន និងទិន្នន័យដែលរដ្ឋបាលសារពើពន្ធមាន។

**ប្រការ៥.- វិធាន និងនីតិវិធីនៃការគណនាចំណូលសរុបពីល្បែង**

អាជីវកម្មល្បែងពាណិជ្ជកម្ម ត្រូវបានចាត់ទុកជាការផ្តល់សេវាជូនដល់ភ្ញៀវល្បែង (អ្នកលេងល្បែង និង/ឬអ្នកផ្សងសំណាង និង/ឬអ្នកភ្នាល់ល្បែង) ដែលជាកម្មវត្ថុនៃការផ្គត់ផ្គង់ជាប់អាករ ហើយចំណូលសរុបពីល្បែង (Gross Gaming Revenue "GGR") គឺជាផលរបររួមទាំងអាករ។

ដើម្បីគណនា **ចំណូលសរុបពីល្បែង (Gross Gaming Revenue "GGR")** ត្រូវយកចំណូលសរុបពីការចាក់ភ្នាល់ដុលដែលបានទទួល ឬត្រូវទទួលពីសកម្មភាពល្បែងពាណិជ្ជកម្មនីមួយៗ ដកចេញនូវប្រាក់ឈ្នះទាំងឡាយណាដែលបានទូទាត់ដល់ភ្ញៀវល្បែង។ ក្នុងករណីផ្តល់រង្វាន់ឱ្យភ្ញៀវល្បែងជាទំនិញ ឬសេវាក្រៅពីសាច់ប្រាក់ មិនត្រូវបានអនុញ្ញាតឱ្យដកចេញសម្រាប់ការគណនាចំណូលសរុបពីល្បែងទេ ប៉ុន្តែចំណាយលើរង្វាន់ជាទំនិញ ឬសេវានេះ ត្រូវបានចាត់ទុកជាចំណាយអាជីវកម្ម និងត្រូវបានអនុញ្ញាតជាចំណាយកាត់កងបានសម្រាប់គោលដៅពន្ធលើប្រាក់ចំណូល ដោយអនុលោមតាមវិធានចំណាយកាត់កងបាននៃបទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់ចំណូល។ ម្យ៉ាងទៀត ការផ្តល់រង្វាន់ឱ្យភ្ញៀវល្បែងជាទំនិញ ឬសេវាក្រៅពីសាច់ប្រាក់ មិនត្រូវបានចាត់ទុកជាការផ្គត់ផ្គង់ទំនិញ ឬសេវានោះទេ។

ដោយឡែក ចំពោះអាករលើតម្លៃបន្ថែមដែលបានបង់លើការទិញទំនិញ ឬសេវាសម្រាប់ផ្តល់ជារង្វាន់ដែលមានវិក្កយបត្រស្របតាមវិធាននៃការប្រើប្រាស់វិក្កយបត្រ ដូចមានចែងក្នុងប្រកាស ៧២៣ សហវ.ប្រក ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ ត្រូវបានអនុញ្ញាតជាឥណទានអាករលើធាតុចូល។

នីតិវិធីនៃការគណនាចំណូលសរុបពីសកម្មភាពល្បែងពាណិជ្ជកម្មនីមួយៗ ត្រូវអនុវត្តដូចតទៅ÷

**ក- ចំណូលសរុបពីល្បែងកាស៊ីណូ**

ដើម្បីគណនាចំណូលសរុបពីល្បែងកាស៊ីណូ សហគ្រាសត្រូវគណនាចំណូលសរុបពីល្បែងទៅតាមតុល្បែងនីមួយៗ និង/ឬម៉ាស៊ីនល្បែងនីមួយៗដាច់ដោយឡែកពីគ្នា និងត្រូវកត់ត្រាលទ្ធផលជាប្រចាំថ្ងៃ បើទោះជាលទ្ធផលចំណូលសរុបពីល្បែងវិជ្ជមាន ឬអវិជ្ជមានក៏ដោយ។ សហគ្រាសត្រូវបូកបញ្ចូលគ្នានូវលទ្ធផលប្រចាំថ្ងៃនៃចំណូលសរុបពីល្បែងកាស៊ីណូគ្រប់ប្រភេទសម្រាប់គណនាចំណូលសរុបពីល្បែងប្រចាំខែដើម្បីប្រកាសបង់ពន្ធ-អាករប្រចាំខែ និងត្រូវមានឯកសារគាំទ្រដើម្បីបញ្ជាក់ពីប្រតិបត្តិការប្រចាំថ្ងៃទៅតាមតុល្បែងនីមួយៗនិង/ឬម៉ាស៊ីនល្បែងនីមួយៗសម្រាប់គោលដៅសវនកម្មពន្ធដារ។

របៀបគណនាលម្អិតសម្រាប់ចំណូលសរុបពីល្បែងកាស៊ីណូតាមតុល្បែងនីមួយៗ និង/ឬម៉ាស៊ីនល្បែងនីមួយៗ ត្រូវអនុវត្តតាមរបៀបនៃការគណនា ដូចមានក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសនេះ។

**ខ- ចំណូលសរុបពីល្បែងផ្សងសំណាង ល្បែងភ្នាល់ និងល្បែងពាណិជ្ជកម្មដទៃទៀតក្រៅពីកាស៊ីណូ**

ដើម្បីគណនាចំណូលសរុបពីល្បែងផ្សងសំណាង ល្បែងភ្នាល់ និងល្បែងពាណិជ្ជកម្មដទៃទៀតក្រៅពីកាស៊ីណូ សហគ្រាសត្រូវកត់ត្រាជាប្រចាំថ្ងៃនូវចំណូលពីការចាក់ភ្នាល់ដែលបានទទួលឬត្រូវទទួល ដកចេញនូវប្រាក់ឈ្នះទាំងឡាយដែលបានទូទាត់ដល់ភ្ញៀវល្បែង បើទោះជាលទ្ធផលចំណូលសរុបពីល្បែងវិជ្ជមាន ឬអវិជ្ជមានក៏ដោយ។ សហគ្រាសត្រូវបូកបញ្ចូលគ្នានូវលទ្ធផលប្រចាំថ្ងៃនៃចំណូលសរុបពីល្បែង សម្រាប់គណនាចំណូលសរុបពីល្បែងប្រចាំខែ ដើម្បីប្រកាសបង់ពន្ធ-អាករប្រចាំខែ និងត្រូវមានឯកសារគាំទ្របញ្ជាក់ពីប្រតិបត្តិការប្រចាំថ្ងៃសម្រាប់គោលដៅសវនកម្មពន្ធដារ។

របៀបនៃការគណនាលម្អិតសម្រាប់ចំណូលសរុបពីល្បែងផ្សងសំណាង ល្បែងភ្នាល់ និងល្បែងពាណិជ្ជកម្មដទៃទៀតក្រៅពីកាស៊ីណូ ត្រូវអនុវត្តដូចមានក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ។

**ប្រការ៦.- មូលដ្ឋានគណនាពន្ធ-អាករប្រចាំខែ**

ដើម្បីគណនាពន្ធ-អាករប្រចាំខែ សហគ្រាសត្រូវបូកសរុបចំណូលសរុបពីល្បែងពីគ្រប់សកម្មភាពល្បែងពាណិជ្ជកម្ម និងគ្រប់ទីតាំងទាំងអស់ ហើយយកទៅកត់ត្រាបញ្ចូលក្នុងបញ្ជីលក់ (ទិនានុប្បវត្តិលក់) ប្រចាំខែ សម្រាប់ដាក់លិខិតប្រកាស និងបង់ពន្ធ-អាករប្រចាំខែ។ ក្នុងករណីលទ្ធផលបូកសរុបចំណូលសរុបពីល្បែងប្រចាំខែខាងលើ អវិជ្ជមាន (ខាត) ត្រូវកត់ត្រាក្នុងបញ្ជីលក់ប្រចាំខែ "សូន្យ" ហើយលទ្ធផលនៃចំណូលសរុបពីល្បែងអវិជ្ជមាន (ខាត) នេះ ត្រូវបានអនុញ្ញាតឱ្យយកទៅដក ដើម្បីគណនាចំណូលសរុបពីល្បែងនៅខែបន្ទាប់។

អនុលោមតាមមាត្រា ២៨ (ថ្មី) និងមាត្រា ៦៤ នៃច្បាប់ស្តីពីសារពើពន្ធ សហគ្រាសប្រកបអាជីវកម្មល្បែងពាណិជ្ជកម្មគ្រប់ប្រភេទ ត្រូវជាប់កាតព្វកិច្ចប្រាក់រំដោះពន្ធលើប្រាក់ចំណូលប្រចាំខែតាមអត្រា ១% និងអាករលើតម្លៃបន្ថែមតាមអត្រា ១០%។

ដើម្បីទទួលបានចំណូលសរុបពីល្បែងពាណិជ្ជកម្មតាមប្រភេទនីមួយៗ សហគ្រាសត្រូវកត់ត្រាចំណូលសរុបពីល្បែងប្រចាំថ្ងៃតាមប្រភេទល្បែង និងទីតាំងនីមួយៗផ្សេងៗគ្នា ដូចមានក្នុង**ឧបសម្ព័ន្ធទី៣** នៃប្រកាសនេះ។

**ប្រការ៧.- ឥណទានអាករលើធាតុចូល**

ឥណទានអាករលើធាតុចូលលើការនាំចូល ឬការទិញក្នុងស្រុក សម្រាប់បម្រើឱ្យសកម្មភាពល្បែងពាណិជ្ជកម្ម ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃមាត្រា២៩ ដល់មាត្រា៤១ នៃអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីអាករលើតម្លៃបន្ថែម។

**ប្រការ៨.- ពន្ធលើប្រាក់ចំណូល**

អនុលោមតាមមាត្រា ២០ ថ្មី (មួយ) នៃច្បាប់ស្តីពីសារពើពន្ធ សហគ្រាសត្រូវជាប់ពន្ធលើប្រាក់ចំណូលតាមអត្រា ២០%។ ផលរបរដែលជាកម្មវត្ថុនៃពន្ធលើប្រាក់ចំណូល គឺជាចំណូលសរុបពីល្បែងពាណិជ្ជកម្មគ្រប់ប្រភេទ និងចំណូលផ្សេងទៀតក្រៅពីចំណូលសរុបពីល្បែងពាណិជ្ជកម្ម លើកលែងតែអាករលើតម្លៃបន្ថែម។

ចំណាយដែលអាចកាត់កងបាន សម្រាប់គោលដៅនៃពន្ធលើប្រាក់ចំណូល ត្រូវអនុវត្តតាមវិធានចំណាយ ដូចមានចែងក្នុងប្រកាសលេខ ០៩៨ សហវ.ប្រក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ ស្តីពីពន្ធលើប្រាក់ចំណូល របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៩.- កាតព្វកិច្ចពន្ធ-អាករដទៃទៀត**

ក្រៅពីពន្ធ-អាករដូចមានចែងក្នុងប្រការ៦ និងប្រការ៨ នៃប្រកាសនេះ សហគ្រាសត្រូវគោរព និងត្រូវបំពេញកាតព្វកិច្ចជាភ្នាក់ងារកាត់ទុក និងប្រកាសបង់ពន្ធលើប្រាក់បៀវត្ស ពន្ធលើអត្ថប្រយោជន៍បន្ថែម ពន្ធកាត់ទុក រួមទាំងពន្ធ-អាករនានា ស្របតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន។

ដោយឡែក ចំពោះសកម្មភាពដទៃទៀតមិនមែនល្បែងពាណិជ្ជកម្ម រួមមាន សណ្ឋាគារ ភោជនីយដ្ឋាន ខារ៉ាអូខេ ម៉ាស្សា ការលក់សំបុត្រចូលទស្សនាផ្សេងៗ ...។ល។ គឺជាសកម្មភាពដាច់ដោយឡែកពីសកម្មភាពល្បែងពាណិជ្ជកម្ម និងត្រូវមានកាតព្វកិច្ចជាប់ពន្ធ-អាករនានា ស្របតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន។

**ប្រការ១០.- ភារកិច្ចកាន់ កត់ត្រា និងថែរក្សាបញ្ជីកាគណនេយ្យ**

សហគ្រាសត្រូវកាន់ កត់ត្រា និងថែរក្សាឯកសារបញ្ជិកាគណនេយ្យ និងព័ត៌មានដែលទាក់ទិននឹងសកម្មភាពអាជីវកម្មល្បែងពាណិជ្ជកម្ម និងសកម្មភាពមិនមែនល្បែងពាណិជ្ជកម្ម ស្របតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងច្បាប់និងបទប្បញ្ញត្តិស្តីពន្ធដារជាធរមាន និងត្រូវរក្សាទុកឯកសារក្នុងរយៈពេល ១០ឆ្នាំ សម្រាប់គោលដៅពន្ធដារ។

**ប្រការ១១.- ភារកិច្ចដាក់លិខិតប្រកាសសារពើពន្ធ និងបង់ប្រាក់ពន្ធ-អាករ**

សហគ្រាសមានសកម្មភាពអាជីវកម្មល្បែងពាណិជ្ជកម្មផង និងសកម្មភាពដទៃទៀតមិនមែនល្បែងពាណិជ្ជកម្មផង ដែលជាប់ពន្ធតាមអត្រាដូចគ្នាត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធ-អាករប្រចាំខែ និងពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ រួមគ្នាតែមួយ ទៅតាមទម្រង់ និងកាលបរិច្ឆេទកំណត់ ស្របតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន ដោយភ្ជាប់មកជាមួយនូវ ឧបសម្ព័ន្ធទី៣ នៃប្រកាសនេះ។

**ប្រការ១២.- ទោសទណ្ឌ**

បុគ្គលទាំងឡាយណាដែលប្រកបអាជីវកម្មល្បែងពាណិជ្ជកម្ម ដែលមិនបានមកចុះបញ្ជី ឬមិនបានមកធ្វើបច្ចុប្បន្នភាពព័ត៌មាន ឬមិនបានដាក់លិខិតប្រកាស ឬមិនបានបង់ប្រាក់ពន្ធ-អាករជូនរដ្ឋបាលសារពើពន្ធ ឬមិនបានបំពេញកាតព្វកិច្ចសារពើពន្ធដទៃទៀត ត្រូវរងទោសទណ្ឌ ដូចមានចែងក្នុងច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន។

**ប្រការ១៣.- និរាករណ៍**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៤.- ការអនុវត្តប្រកាស**

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋាន ឬអគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃសុក្រ ៨កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ ១៤ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ឧបសម្ព័ន្ធទី១ នៃប្រកាសលេខ ១០.ទ.០៧ហ.វ.ប្រក ចុះថ្ងៃទី...៣០....ខែ ...តុលា.......ឆ្នាំ ២០២២**

**របៀបគណនាលម្អិតសម្រាប់ចំណូលសរុបតាមតុល្បែងនីមួយៗ និងម៉ាស៊ីនល្បែងនីមួយៗ**

## (ក) របៀបគណនាចំណូលសរុបពីតុល្បែងនីមួយៗប្រចាំថ្ងៃ

ដើម្បីគណនាចំណូលសរុបពីតុល្បែង កាស៊ីណូត្រូវប្រើរូបមន្តដូចខាងក្រោម÷

**ចំណូលសរុបពីតុល្បែង= សារពើភណ្ឌតុចុងគ្រា+ ឥណទាន+ ទម្លាក់- សារពើភណ្ឌតុដើមគ្រា- ហ្វិល**

- សារពើភណ្ឌតុចុងគ្រា (closing table inventory)÷ ជាចំនួនកាក់ល្បែងដែលនៅក្នុងថាស (tray) នៅពេលដែលវេនលេងត្រូវបានបញ្ចប់។
- ឥណទាន (Credits)÷ អាចជាទឹកប្រាក់ ជាកាក់ល្បែង ឬជាថូខិន ដែលត្រូវបានដកចេញពីតុល្បែងហើយបញ្ជូនទៅខេច (Cage) វិញ។
- ទម្លាក់ (Drop)÷ ជាចំនួនសរុបនៃទឹកប្រាក់ កាក់ល្បែង (Chips) ថូកខិន (Tokens) និងឥណទានទាំងឡាយនៅក្នុងប្រអប់ទម្លាក់ (Drop box)។
- សារពើភណ្ឌតុដើមគ្រា (open table inventory)÷ ជាចំនួនកាក់ល្បែងដែលនៅក្នុងថាស (tray) នៅពេលដែលវេនលេងចាប់ផ្តើម។
- ហ្វិល (Fills)÷ ជាកាក់ល្បែងដែលបានបញ្ជូនមកលើតុល្បែងពីខេច (Cage)។

### ឧទាហរណ៍ទី១ ការទទួលស្គាល់ចំណូលសរុបពីតុល្បែងមួយ (A01) ប្រចាំថ្ងៃ (ចំណេញ) ÷

នៅថ្ងៃទី០១ ខែកុម្ភៈ តុល្បែង A01 ចាប់ផ្តើមប្រតិបត្តិការប្រចាំថ្ងៃ ដោយតុល្បែងមានសារពើភណ្ឌតុដើមគ្រាចំនួន 1,200 ដុល្លារ។ នៅពេលបិទបញ្ជីប្រចាំថ្ងៃ ប្រអប់ទម្លាក់នៅតុល្បែង (Drop box) មានសាច់ប្រាក់ចំនួន 8,000 ដុល្លារ ឥណទាន (Credits) ចំនួន 3,000 ដុល្លារ ហ្វិល (Fills) ចំនួន 2,000 ដុល្លារ និងសារពើភណ្ឌតុចុងគ្រាចំនួន 1,000 ដុល្លារ។

ដូច្នេះ ចំណូលសរុបពីតុល្បែង A01 នៅថ្ងៃទី០១ ខែកុម្ភៈ ត្រូវគណនាដូចខាងក្រោម÷

| | | |
|---|---|---|
| **សារពើភណ្ឌតុចុងគ្រា** | (a) | 1,000 |
| **ឥណទាន** | (b) | 3,000 |
| **ទម្លាក់** | (c) | 8,000 |
| **សារពើភណ្ឌតុដើមគ្រា** | (d) | 1,200 |
| **ហ្វិល** | (e) | 2,000 |
| **ចំណូលសរុបពីតុល្បែង**<br>f = (a + b + c - d - e) | | **8,800** |

### ឧទាហរណ៍ទី២ ការទទួលស្គាល់ចំណូលសរុបពីតុល្បែងមួយ (A02) ប្រចាំថ្ងៃ (ខាត) ÷

នៅថ្ងៃទី០១ ខែកុម្ភៈ តុល្បែង A02 ចាប់ផ្តើមប្រតិបត្តិការប្រចាំថ្ងៃ ដោយតុល្បែងមានសារពើភណ្ឌតុដើមគ្រាចំនួន 700 ដុល្លារ។ នៅពេលបិទបញ្ជីប្រចាំថ្ងៃ ក្នុងប្រអប់ទម្លាក់នៅតុល្បែង (Drop box) មានសាច់ប្រាក់ចំនួន 500 ដុល្លារ ឥណទាន (Credits) ចំនួន 1,500 ដុល្លារ ហ្វិល (Fills) ចំនួន 1,600 ដុល្លារ និងសារពើភណ្ឌតុចុងគ្រាចំនួន 600 ដុល្លារ។

ដូច្នេះ ចំណូលសរុបពីតុល្បែង A02 នៅថ្ងៃទី០២ ខែកុម្ភៈ ត្រូវគណនាដូចខាងក្រោម÷

| | | |
|---|---|---|
| **សារពើភណ្ឌតុចុងគ្រា** | (a) | 600 |
| **ឥណទាន** | (b) | 700 |
| **ទម្លាក់** | (c) | 500 |
| **សារពើភណ្ឌតុដើមគ្រា** | (d) | 1,000 |
| **ហ្វិល** | (e) | 1,600 |
| **ចំណូលសរុបពីតុល្បែង**<br>f = (a + b + c - d - e) | | **(800)** |

**ឧទាហរណ៍ទី៣  ការទទួលស្គាល់ចំណូលសរុបពីតុល្បែងទាំងអស់ ប្រចាំថ្ងៃ÷**

នៅថ្ងៃទី០១ ខែកុម្ភៈ អត្រាប្តូរប្រាក់ ១ដុល្លារ ស្មើ ៤ ០០០រៀល កាស៊ីណូមានតុល្បែងទាំងអស់ចំនួន១០ (A01 ដល់ A10) ដែលមានរបាយការណ៍បិទបញ្ជីប្រចាំថ្ងៃដូចខាងក្រោម÷

| **ថ្ងៃទី ០១ ខែកុម្ភៈ** | | **A01** | **A02** | **A03** | **....** | **A10** | **សរុប(ដុល្លារ)** | **សរុប(រៀល)** |
|---|---|---|---|---|---|---|---|---|
| សារពើភណ្ឌតុចុងគ្រា | (a) | 1,000 | 600 | 26,000 | - | 36,000 | 63,600 | **254,400,000** |
| ឥណទាន | (b) | 3,000 | 700 | 200 | - | 7,500 | 11,400 | **45,600,000** |
| ទម្លាក់ | (c) | 8,000 | 500 | 5,000 | - | 5,000 | 18,500 | **74,000,000** |
| សារពើភណ្ឌតុដើមគ្រា | (d) | 1,200 | 1,000 | 1,500 | - | 30,000 | 33,700 | **134,800,000** |
| ហ្វិល | (e) | 2,000 | 1,600 | 11,200 | - | 15,000 | 29,800 | **119,200,000** |
| ចំណូលសរុបពីតុល្បែង<br>f = (a+b+c-d-e) | | **8,800** | **(800)** | **18,500** | **-** | **3,500** | **30,000** | **120,000,000** |

**សំគាល់÷ តួលេខសរុបជាប្រាក់រៀលក្នុងជួរឈរតារាងនេះ ត្រូវស្រង់យកទៅបំពេញនៅក្នុងតារាងទី១ក (ប្រតិបត្តិការចំណូលសរុបប្រចាំថ្ងៃពីតុល្បែងក្នុងខែ) នៃឧបសម្ព័ន្ធទី៣។*

**(ខ) របៀបគណនាចំណូលសរុបពីម៉ាស៊ីនល្បែងនីមួយៗប្រចាំថ្ងៃ**

ដើម្បីធ្វើគណនាចំណូលសរុបពីម៉ាស៊ីនល្បែង កាស៊ីណូប្រើប្រាស់រូបមន្តដូចខាងក្រោម÷

**ចំណូលសរុបពីម៉ាស៊ីនល្បែង = ទម្លាក់ (Drop) - ការកាត់បន្ថយ (Deduction and timing issues)**

- ទម្លាក់ (Drop) គឺជាទឹកប្រាក់ក្នុងស្តុតម៉ាស៊ីនដែលបានមកពី÷
  - ហ្វិល (Fills) គឺជាកាក់ល្បែងដែលត្រូវបំពេញក្នុងម៉ាស៊ីនពីខេច (Cage)
  - លុយក្នុងម៉ាស៊ីនដែលបានពីអតិថិជន អាចជាទឹកប្រាក់បានមកពី ប៊ីលវ៉ាលីដេតទ័រ (Bill validator) ធីកឃីតវូចឈ័រ (Ticket voucher) កាក់ល្បែង ឬប្រាក់ផ្ទេរតាមអេឡិចត្រូនិក
- ការកាត់បន្ថយ (Deduction and timing issues)÷
  - ហ្វិល (Fills) គឺជាទឹកប្រាក់ស្តុកទុកសម្រាប់ក្នុងម៉ាស៊ីនដែលមិនមែនបានមកពីអតិថិជន
  - សំបុត្រចេញ (Paid-out ticket), Jackpots បង់ដោយដៃ (Hand-paid Jackpots), ការផ្ទេរពីគណនីភ្ញាល់ទៅអតិថិជន
  - ចំនួនផ្លាស់ប្តូរសុទ្ធនៃ Hopper balance (ចំនួនឈ្នះសុទ្ធ ឬចាញ់សុទ្ធនៃកាក់)។

**ឧទាហរណ៍ទី៤ ការទទួលស្គាល់ចំណូលសរុបពីម៉ាស៊ីនល្បែងមួយ (M01) ប្រចាំថ្ងៃ ( ចំណេញ) ÷**

ថ្ងៃទី០១ ខែកុម្ភៈ នៅពេលបិទបញ្ជីប្រចាំថ្ងៃ ម៉ាស៊ីនល្បែង M01 មានកាក់ល្បែងនៅក្នុងធុងទម្លាក់ចំនួន 6,000 ដុល្លារ សាច់ប្រាក់ក្នុងម៉ាស៊ីនទទួលពីអតិថិជនចំនួន 5,000 ដុល្លារ និងបានទូទាត់ដោយ សំបុត្រចេញចំនួន 2,500 ដុល្លារ និង Jackpots បង់ដោយដៃចំនួន 5,600 ដុល្លារ។ ដោយឡែក របាយការណ៍ចំនួនផ្លាស់ប្តូរសុទ្ធនៃ Hopper balance (1,400) ដុល្លារ។

ដូច្នេះ ចំណូលសរុបពីម៉ាស៊ីនល្បែង M01 នៅថ្ងៃទី០១ ខែកុម្ភៈ ត្រូវគណនាដូចខាងក្រោម÷

| | |
|---|---|
| **ទម្លាក់ (Drop)** | |
| កាក់ល្បែងនៅក្នុងធុងទម្លាក់ | 6,000 |
| សាច់ប្រាក់ក្នុងម៉ាស៊ីនទទួលពីអតិថិជន | 5,000 |
| **ទម្លាក់សរុប (a)** | **11,000** |
| **ការកាត់បន្ថយ (Deduction and timing issues)** | |
| សំបុត្រចេញ | 2,500 |
| Jackpots បង់ដោយដៃ | 5,600 |
| ចំនួនផ្លាស់ប្តូរសុទ្ធនៃ Hopper balance | (1,400) |
| **ការកាត់បន្ថយសរុប (b)** | **6,700** |
| **ចំណូលសរុបពីម៉ាស៊ីនល្បែង ( c = a - b )** | **4,300** |

**ឧទាហរណ៍ទី៥ ការទទួលស្គាល់ចំណូលសរុបពីម៉ាស៊ីនល្បែងមួយ (M02) ប្រចាំថ្ងៃ ( ខាត) ÷**

ថ្ងៃទី០១ ខែកុម្ភៈ នៅពេលបិទបញ្ជីប្រចាំថ្ងៃ ម៉ាស៊ីនល្បែង M02 មានកាក់ល្បែងនៅក្នុងធុងទម្លាក់ចំនួន 800 ដុល្លារ សាច់ប្រាក់ក្នុងម៉ាស៊ីនទទួលពីអតិថិជនចំនួន 4,000 ដុល្លារ សាច់ប្រាក់ទទួលបានពីអតិថិជនតាមអេឡិចត្រូនិក 3,000 ដុល្លារ និងបានទូទាត់ដោយ សំបុត្រចេញចំនួន 3,000 ដុល្លារ Jackpots បង់ដោយដៃចំនួន 5,500 ដុល្លារ និងសាច់ប្រាក់បញ្ជូនតាមប្រព័ន្ធអេឡិចត្រូនិកពីម៉ាស៊ីនល្បែងទៅគណនីភ្នាល់ចំនួន 4,600 ដុល្លារ។ ដោយឡែក របាយការណ៍ចំនួនផ្លាស់ ប្តូរសុទ្ធនៃ Hopper balance 800 ដុល្លារ។

| | |
|---|---|
| ទម្លាក់ (Drop) | |
| កាក់ល្បែងនៅក្នុងធុងទម្លាក់ | 800 |
| សាច់ប្រាក់ក្នុងម៉ាស៊ីនទទួលពីអតិថិជន | 4,000 |
| សាច់ប្រាក់ទទួលបានពីអតិថិជនតាមអេឡិចត្រូនិក | 3,000 |
| **ទម្លាក់សរុប (a)** | 7,800 |
| ការកាត់បន្ថយ (Deduction and timing issues) | |
| សំបុត្រចេញ | 3,000 |
| Jackpots បង់ដោយដៃ | 5,500 |
| សាច់ប្រាក់បញ្ជូនតាមប្រព័ន្ធអេឡិចត្រូនិកពីម៉ាស៊ីនល្បែងទៅគណនីភ្នាល់ | 4,600 |
| ចំនួនផ្លាស់ប្តូរសុទ្ធនៃ Hopper balance | 800 |
| **ការកាត់បន្ថយសរុប (b)** | 13,900 |
| **ចំណូលសរុបពីម៉ាស៊ីនល្បែង ( c = a - b )** | **(6,100)** |

**ឧទាហរណ៍ទី៦ ការទទួលស្គាល់ចំណូលសរុបពីម៉ាស៊ីនល្បែងទាំងអស់ ប្រចាំថ្ងៃ÷**

នៅថ្ងៃទី០១ ខែកុម្ភៈ អត្រាប្តូរប្រាក់ ១ដុល្លារ ស្មើ ៤ ០០០រៀល កាស៊ីណូមានម៉ាស៊ីនល្បែងទាំងអស់ចំនួន ១០ (M01 ដល់ M10) ដែលមានរបាយការណ៍បិទបញ្ជីប្រចាំថ្ងៃដូចខាងក្រោម÷

| ថ្ងៃទី ០១ ខែកុម្ភៈ | M01 | M02 | M03 | ... | M10 | សរុប (ដុល្លារ) | សរុប (រៀល) |
|---|---|---|---|---|---|---|---|
| កាក់ល្បែងនៅក្នុងធុងទម្លាក់ | 6,000 | 800 | 2,000 | - | 1,270 | 10,070 | **40,280,000** |
| សាច់ប្រាក់ក្នុងម៉ាស៊ីនទទួលពីអតិថិជន | 5,000 | 4,000 | 3,930 | - | 7,600 | 20,530 | **82,120,000** |
| សាច់ប្រាក់ទទួលបានពីអតិថិជនតាមអេឡិចត្រូនិក | - | 3,000 | 3,830 | | - | 6,830 | **27,320,000** |
| **ទម្លាក់សរុប (a)** | **11,000** | **7,800** | **9,760** | **-** | **8,870** | **37,430** | **149,720,000** |
| សំបុត្រចេញ | 2,500 | 3,000 | 20 | - | 65 | 5,585 | **22,340,000** |
| ហ្វីល | - | - | - | - | 500 | 500 | **2,000,000** |
| Jackpots បង់ដោយដៃ | 5,600 | 5,500 | 750 | - | 245 | 12,095 | **48,380,000** |
| សាច់ប្រាក់បញ្ជូនតាមប្រព័ន្ធអេឡិចត្រូនិកពីម៉ាស៊ីនល្បែងទៅគណនីភ្នាល់ | - | 4,600 | - | - | - | 4,600 | **18,400,000** |
| ចំនួនផ្លាស់ប្តូរសុទ្ធនៃ Hopper balance | (1,400) | 800 | 30 | - | 220 | (350) | **(1,400,000)** |
| **ការកាត់បន្ថយសរុប (b)** | **6,700** | **13,900** | **800** | **-** | **1,030** | **22,430** | **89,720,000** |
| **ចំណូលសរុបពីម៉ាស៊ីនល្បែង ( c = a - b )** | **4,300** | **(6,100)** | **8,960** | **-** | **7,840** | **15,000** | **60,000,000** |

**សំគាល់÷ តួលេខសរុបជាប្រាក់រៀលក្នុងជួរឈរតារាងនេះ ត្រូវស្រង់យកទៅបំពេញនៅក្នុងតារាងទី១ខ (ប្រតិបត្តិការចំណូលសរុបប្រចាំថ្ងៃពីម៉ាស៊ីនល្បែងក្នុងខែ) នៃឧបសម្ព័ន្ធទី៣។*

**ឧទាហរណ៍ទី៧ ករណីមានចំណូលសរុបពីល្បែងវិជ្ជមាន÷**

នៅថ្ងៃទី០១ ខែកុម្ភៈ ចំណូលសរុបពីតុល្បែងទាំងអស់ មានចំនួន 120,000,000 រៀល (ដូចលទ្ធផលគណនាក្នុងឧទាហរណ៍ទី៣) និងចំណូលសរុបពី ម៉ាស៊ីនល្បែងទាំងអស់ មានចំនួន 60,000,000 រៀល (ដូចលទ្ធផលគណនាក្នុងឧទាហរណ៍ទី៦) ដែលមានចំណូលសរុបពីល្បែង (GGR) ប្រចាំថ្ងៃចំនួន 180,000,000 រៀល។ នៅថ្ងៃបន្តបន្ទាប់មកទៀត កាស៊ីណូ មានចំណូលសរុបពីតុល្បែង និងម៉ាស៊ីនល្បែងទាំងអស់ ព្រមទាំងចំណូលសរុបពីល្បែង (GGR) ប្រចាំថ្ងៃនីមួយៗ ដូចខាងក្រោម÷

| ប្រចាំថ្ងៃ | ចំណូលសរុបពី តុល្បែងទាំងអស់ | ចំណូលសរុបពី ម៉ាស៊ីនល្បែងទាំងអស់ | ចំណូលសរុបពីល្បែង ឈ្នះ/(ចាញ់) |
|---|---|---|---|
| ថ្ងៃទី០១ ខែកុម្ភៈ | 120,000,000 | 60,000,000 | 180,000,000 |
| ថ្ងៃទី០២ ខែកុម្ភៈ | 250,000,000 | 110,000,000 | 360,000,000 |
| ថ្ងៃទី០៣ ខែកុម្ភៈ | (24,000,000) | (8,000,000) | (32,000,000) |
| ... | ... | ... | ... |
| ថ្ងៃទី២៧ ខែកុម្ភៈ | 150,000,000 | 120,200,000 | 270,200,000 |
| ថ្ងៃទី២៨ ខែកុម្ភៈ | (36,000,000) | 8,000,000 | (28,000,000) |
| សរុបប្រចាំខែកុម្ភៈ | **460,000,000** | **290,200,000** | **750,200,000** |

កាស៊ីណូ *កខគ* ត្រូវធ្វើការគណនាប្រាក់ពន្ធ-អាករ ចំពោះចំណូលពីល្បែងពាណិជ្ជកម្ម សម្រាប់ខែ**កុម្ភៈ** ដូចខាងក្រោម÷

**១. អាករលើតម្លៃបន្ថែម អត្រា ១០% ÷**

មូលដ្ឋានគិតអាករលើតម្លៃបន្ថែម = ចំណូលសរុបពីតុល្បែង និងម៉ាស៊ីនល្បែងប្រចាំខែ / 1.1

= 750,200,000 / 1.1 = 682,000,000 រៀល

ដូចនេះ អាករលើតម្លៃបន្ថែម = មូលដ្ឋានគិតអាករលើតម្លៃបន្ថែម x អត្រា ១០%

= 682,000,000 * 10% = 68,200,000 រៀល

**២. ប្រាក់រំដោះពន្ធលើប្រាក់ចំណូល អត្រា ១% ÷**

មូលដ្ឋានគិតប្រាក់រំដោះ = ចំណូលសរុបពីតុល្បែង និងម៉ាស៊ីនល្បែង - អាករលើតម្លៃបន្ថែម

= 750,200,000 - 68,200,000 = 682,000,000 រៀល

ដូចនេះ ប្រាក់រំដោះពន្ធលើប្រាក់ចំណូល = មូលដ្ឋានគិតប្រាក់រំដោះ x អត្រា ១%

= 682,000,000 * 1% = 6,820,000 រៀល

**ឧទាហរណ៍ទី៨ ករណីមានចំណូលសរុបពីល្បែងអវិជ្ជមាន (ខាត) ឬស្មើសូន្យ ÷**

ក្នុងខែមីនា កាស៊ីណូ *កខគ* មានចំណូលសរុបពីតុល្បែង និងម៉ាស៊ីនល្បែងទាំងអស់ ព្រមទាំងចំណូលសរុបពីល្បែង (GGR) ប្រចាំថ្ងៃនីមួយៗ ដូចខាងក្រោម÷

| ប្រចាំថ្ងៃ | ចំណូលសរុបពី តុល្បែងទាំងអស់ គិតជារៀល | ចំណូលសរុបពី ម៉ាស៊ីន ល្បែងទាំងអស់ គិតជារៀល | ចំណូលសរុបពីល្បែង ឈ្នះ/(ចាញ់) គិតជារៀល |
|---|---|---|---|
| ថ្ងៃទី០១ ខែមីនា | 20,000,000 | 25,000,000 | 45,000,000 |
| ថ្ងៃទី០២ ខែមីនា | 5,000,000 | (60,000,000) | (55,000,000) |
| ថ្ងៃទី០៣ ខែមីនា | (3,000,000) | 30,000,000 | 27,000,000 |
| ... | ... | ... | ... |
| ថ្ងៃទី៣០ ខែមីនា | 6,000,000 | 9,000,000 | 15,000,000 |
| ថ្ងៃទី៣១ ខែមីនា | (23,000,000) | (55,000,000) | (78,000,000) |
| **សរុបប្រចាំខែមីនា** | **5,000,000** | **(51,000,000)** | **(46,000,000)** |

ដូច្នេះ នៅក្នុងខែមីនា កាស៊ីណូ *កខគ* មានចំណូលសរុបពីល្បែង (ចំណូលសរុបពីតុល្បែងទាំងអស់ **បូក** ចំណូលសរុបពីម៉ាស៊ីនល្បែងទាំងអស់) **អវិជ្ជមាន (ខាត)** ចំនួន **(46,000,000) រៀល** ។

កាស៊ីណូ *កខគ* ត្រូវធ្វើការគណនាប្រាក់ពន្ធ-អាករ ចំពោះចំណូលពីល្បែងពាណិជ្ជកម្ម សម្រាប់ខែ**មីនា** ដូចខាងក្រោម÷

**១. អាករលើតម្លៃបន្ថែម អត្រា ១០% ÷**

មូលដ្ឋានគិតអាករលើតម្លៃបន្ថែម = 0 រៀល

ដូចនេះ អាករលើតម្លៃបន្ថែម = 0 រៀល

**២. ប្រាក់រំដោះពន្ធលើប្រាក់ចំណូល អត្រា ១% ÷**

មូលដ្ឋានគិតប្រាក់រំដោះ = 0 រៀល

ដូចនេះប្រាក់រំដោះពន្ធលើប្រាក់ចំណូល = 0 រៀល

**ឧទាហរណ៍ទី៩ ករណីមានខាតពីខែមុន ÷**

នៅក្នុងខែមេសា កាស៊ីណូ ***កខគ*** មានចំណូលសរុបពីតុល្បែង និងម៉ាស៊ីនល្បែង ប្រចាំថ្ងៃមាន ដូចខាងក្រោម÷

| ប្រចាំថ្ងៃ | ចំណូលសរុបពីតុល្បែង និងម៉ាស៊ីនល្បែង ឈ្នះ/(ចាញ់) គិតជារៀល |
|---|---|
| ថ្ងៃទី០១ ខែមេសា | 256,000,000 |
| ថ្ងៃទី០២ ខែមេសា | (129,000,000) |
| ថ្ងៃទី០៣ ខែមេសា | 355,000,000 |
| ... | ... |
| ថ្ងៃទី២៩ ខែមេសា | 345,500,000 |
| ថ្ងៃទី៣០ ខែមេសា | 247,000,000 |
| **សរុបប្រចាំខែមេសា** | **1,074,500,000** |

កាស៊ីណូ ***កខគ*** ត្រូវធ្វើការគណនាប្រាក់ពន្ធ-អាករ ចំពោះចំណូលពីល្បែងពាណិជ្ជកម្ម សម្រាប់ខែ**មេសា** ដូចខាងក្រោម÷

| | |
|---|---|
| ចំណូលសរុបពីល្បែងពាណិជ្ជកម្មអវិជ្ជមាន (ខាត) ពីខែមុន (មីនា) | (46,000,000) រៀល |
| ចំណូលសរុបពីតុល្បែង និងម៉ាស៊ីនល្បែងក្នុងខែមេសា | 1,074,500,000 រៀល |
| ចំណូលសរុបពីតុល្បែង និងម៉ាស៊ីនល្បែង | **1,028,500,000 រៀល** |

**១. អាករលើតម្លៃបន្ថែម អត្រា ១០% ÷**

មូលដ្ឋានគិតអាករលើតម្លៃបន្ថែម = 1,028,500,000/ 1.1 = 935,000,000 រៀល

ដូចនេះ អាករលើតម្លៃបន្ថែម = 935,000,000 * 10% = 93,500,000 រៀល

**២. ប្រាក់រំដោះពន្ធលើប្រាក់ចំណូល អត្រា ១% ÷**

មូលដ្ឋានគិតពន្ធ = 1,028,500,000 - 93,500,000 = 935,000,000 រៀល

ដូចនេះប្រាក់រំដោះពន្ធលើប្រាក់ចំណូល = 935,000,000 * 1% = 9,350,000 រៀល

**ឧបសម្ព័ន្ធទី២ នៃប្រកាសលេខ...ចុះថ្ងៃទី...ខែ...ឆ្នាំ...**

## របៀបគណនាលម្អិតសម្រាប់ចំណូលសរុបពីល្បែងផ្សងសំណាង ល្បែងភ្នាល់ និងល្បែងពាណិជ្ជកម្មដទៃទៀតក្រៅពីកាស៊ីណូ

ដើម្បីគណនាចំណូលសរុបពីល្បែងផ្សងសំណាង ល្បែងភ្នាល់ និងល្បែងពាណិជ្ជកម្មដទៃទៀតក្រៅពីកាស៊ីណូ សហគ្រាសត្រូវប្រើរូបមន្តដូចខាងក្រោម÷

**ចំណូលសរុបពីល្បែង = ប្រាក់ចាក់ភ្នាល់ដែលបានទទួលឬត្រូវទទួល - ប្រាក់ឈ្នះបានទូទាត់ឱ្យភ្ញៀវល្បែង**

**ឧទាហរណ៍ទី១០ ការទទួលស្គាល់ចំណូលសរុបពីល្បែងផ្សងសំណាងប្រចាំថ្ងៃ÷**

នៅថ្ងៃទី០១ ខែកុម្ភៈ ក្រុមហ៊ុន Lotto ***កខគ*** ទទួលបានចំណូលពីការលក់ឆ្នោតផ្សងសំណាងចំនួន 2,500 ដុល្លារ និងបានទូទាត់ប្រាក់ឈ្នះជូនអតិថិជន ចំពោះលទ្ធផលឆ្នោតដែលបានប្រកាសនៅថ្ងៃទី២៥ ខែមករា ចំនួន 11,250 ដុល្លារ ដែលមានអត្រាប្តូរប្រាក់ ១ដុល្លារ ស្មើ ៤ ០០០រៀល ។

ដូច្នេះ ចំណូលសរុបពីល្បែងជាប្រាក់រៀលប្រចាំថ្ងៃទី០១ ខែកុម្ភៈ÷

| | | | |
|---|---|---|---|
| | ចំណូលពីការចាក់ភ្នាល់ | = 2,500 x 4,000 | = 10,000,000 រៀល |
| ដក: | ប្រាក់ឈ្នះបានទូទាត់ | = 11,250 x 4,000 | = 45,000,000 រៀល |
| | | **ចំណូលសរុបពីល្បែង** | **= (35,000,000) រៀល** |

**ឧទាហរណ៍ទី១១ ករណីមានចំណូលសរុបពីល្បែងវិជ្ជមាន (ចំណេញ) ÷**

នៅថ្ងៃទី០១ ខែកុម្ភៈ ក្រុមហ៊ុន Lotto កខគ មានចំណូលពីការលក់ឆ្នោតផ្សងសំណាងចំនួន 10,000,000 រៀល និងបានទូទាត់ប្រាក់ឈ្នះជូនអតិថិជនចំនួន 45,000,000 រៀល។ ក្រោយការគណនា ក្រុមហ៊ុនមានចំណូលសរុបពីល្បែងប្រចាំថ្ងៃខាតចំនួន (35,000,000) រៀល (ដូចលទ្ធផលគណនាក្នុងឧទាហរណ៍ទី១០)។

នៅថ្ងៃបន្តបន្ទាប់មកទៀត ក្រុមហ៊ុនមានចំណូលពីការលក់ឆ្នោតផ្សងសំណាង និងបានទូទាត់ប្រាក់ឈ្នះជូនអតិថិជន ហើយមានចំណូលសរុបពីល្បែង (GGR) ប្រចាំថ្ងៃនីមួយៗ ដូចខាងក្រោម÷

| ប្រចាំថ្ងៃ | ចំណូលចាក់ភ្នាល់ | ប្រាក់ឈ្នះបានទូទាត់ | ចំណូលសរុបពីល្បែងភ្នាល់ |
|---|---|---|---|
| | (a) | (b) | (c = a - b) |
| ថ្ងៃទី០១ ខែកុម្ភៈ | 10,000,000 | 45,000,000 | (35,000,000) |
| ថ្ងៃទី០២ ខែកុម្ភៈ | 28,000,000 | - | 28,000,000 |
| ថ្ងៃទី០៣ ខែកុម្ភៈ | 17,000,000 | - | 17,000,000 |
| ... | - | - | ... |
| ថ្ងៃទី១៥ ខែកុម្ភៈ | 18,000,000 | 45,000,000 | (27,000,000) |
| ... | - | - | ... |
| ថ្ងៃទី២៧ ខែកុម្ភៈ | 18,000,000 | - | 18,000,000 |
| ថ្ងៃទី២៨ ខែកុម្ភៈ | 17,150,000 | - | 17,150,000 |
| **សរុបប្រចាំខែកុម្ភៈ** | **108,150,000** | **90,000,000** | **18,150,000** |

ក្រុមហ៊ុន Lotto ***កខគ*** ត្រូវធ្វើការគណនាប្រាក់ពន្ធ-អាករ ចំពោះចំណូលពីល្បែងពាណិជ្ជកម្ម សម្រាប់ខែកុម្ភៈ ដូចខាងក្រោម÷

**១. អាករលើតម្លៃបន្ថែម អត្រា ១០%÷**

មូលដ្ឋានគិតអាករលើតម្លៃបន្ថែម = ចំណូលសរុបពីល្បែងភ្នាល់ប្រចាំខែ / 1.1

= 18,150,000 / 1.1 = 16,500,000 រៀល

ដូចនេះអាករលើតម្លៃបន្ថែម = មូលដ្ឋានគិតអាករលើតម្លៃបន្ថែម x អត្រា ១០%

= 16,500,000 * 10% = 1,650,000 រៀល

**២. ប្រាក់រំដោះពន្ធលើប្រាក់ចំណូល អត្រា ១%÷**

មូលដ្ឋានគិតប្រាក់រំដោះ = ចំណូលសរុបពីល្បែងភ្នាល់ប្រចាំខែ - អាករលើតម្លៃបន្ថែម

= 18,150,000 - 1,650,000 = 16,500,000 រៀល

ដូចនេះប្រាក់រំដោះពន្ធលើប្រាក់ចំណូល = មូលដ្ឋានគិតប្រាក់រំដោះ x អត្រា ១%

= 16,500,000 * 1% = 165,000 រៀល

**ឧទាហរណ៍ទី១២ ករណីមានចំណូលសរុបពីល្បែងអវិជ្ជមាន (ខាត) ឬស្មើសូន្យ÷**

នៅក្នុងខែមីនា ក្រុមហ៊ុន Lotto ***កខគ*** ទទួលបានចំណូលពីការលក់ឆ្នោតផ្សងសំណាង និងបានទូទាត់ប្រាក់ឈ្នះជូនអតិថិជន ហើយមានចំណូលសរុបពីល្បែង (GGR) ប្រចាំថ្ងៃនីមួយៗ ដូចខាងក្រោម÷

| **ប្រចាំថ្ងៃ** | **ប្រាក់ចាក់ភ្នាល់ គិតជារៀល** | **ប្រាក់ឈ្នះបានទូទាត់ គិតជារៀល** | **ចំណូលសរុបពីល្បែងភ្នាល់ គិតជារៀល** |
|---|---|---|---|
| | (a) | (b) | ( c = a - b ) |
| ថ្ងៃទី០១ ខែមីនា | 10,000,000 | - | 10,000,000 |
| ថ្ងៃទី០២ ខែមីនា | 8,000,000 | *20,000,000** | (12,000,000) |
| ថ្ងៃទី០៣ ខែមីនា | 15,000,000 | - | 15,000,000 |
| ... | - | - | ... |
| ថ្ងៃទី១៥ ខែមីនា | 5,000,000 | 25,000,000 | (20,000,000) |
| ... | - | - | ... |
| ថ្ងៃទី៣០ ខែមីនា | 18,000,000 | - | 18,000,000 |
| ថ្ងៃទី៣១ ខែមីនា | 9,000,000 | 25,000,000 | (16,000,000) |
| **សរុបប្រចាំខែមីនា** | **65,000,000** | **70,000,000** | **(5,000,000)** |

** សន្លឹកឆ្នោតឈ្នះនៅក្នុងខែកុម្ភៈ ប៉ុន្តែអតិថិជនបើករង្វាន់នៅខែមីនា*

នៅក្នុងខែមីនា ចំណូលសរុបពីល្បែងភ្នាល់ប្រចាំខែ អវិជ្ជមាន (ខាត) ចំនួន **(5,000,000) រៀល** ។ ដូច្នេះក្រុមហ៊ុន Lotto ***កខគ*** ត្រូវធ្វើការប្រកាសនិងបង់ប្រាក់ពន្ធ-អាករសម្រាប់ខែមីនា ដូចតទៅ÷

**១. អាករលើតម្លៃបន្ថែម អត្រា ១០%÷**

មូលដ្ឋានគិតអាករលើតម្លៃបន្ថែម = 0 រៀល

ដូចនេះអាករលើតម្លៃបន្ថែម = **0 រៀល**

**២. ប្រាក់រំដោះពន្ធលើប្រាក់ចំណូល អត្រា ១%÷**

មូលដ្ឋានគិតប្រាក់រំដោះ = 0 រៀល

ដូចនេះប្រាក់រំដោះពន្ធលើប្រាក់ចំណូល = **0 រៀល**

**ឧទាហរណ៍ទី១៣ ករណីមានខាតពីខែមុន ÷**

នៅក្នុងខែមេសា ក្រុមហ៊ុន Lotto ***កខគ*** ទទួលបានចំណូលពីការលក់ឆ្នោតផ្សងសំណាង និងបានទូទាត់ប្រាក់ឈ្នះជូនអតិថិជន ហើយមានចំណូលសរុបពីល្បែង (GGR) ប្រចាំថ្ងៃនីមួយៗ ដូចខាងក្រោម÷

| ប្រចាំថ្ងៃ | ប្រាក់ចាក់ភ្នាល់ គិតជារៀល | ប្រាក់ឈ្នះបានទូទាត់ គិតជារៀល | ចំណូលសរុបពីល្បែងភ្នាល់ គិតជារៀល |
|---|---|---|---|
| | (a) | (b) | ( c = a - b ) |
| ថ្ងៃទី០១ ខែមេសា | 10,000,000 | - | 10,000,000 |
| ថ្ងៃទី០២ ខែមេសា | 8,000,000 | - | 8,000,000 |
| ថ្ងៃទី០៣ ខែមេសា | 15,000,000 | - | 15,000,000 |
| ... | - | - | ... |
| ថ្ងៃទី១៥ ខែមេសា | 5,000,000 | 37,000,000 | (32,000,000) |
| ... | - | - | ... |
| ថ្ងៃទី២៩ ខែមេសា | 18,000,000 | - | 18,000,000 |
| ថ្ងៃទី៣០ ខែមេសា | 28,100,000 | 30,000,000 | (1,900,000) |
| **សរុបប្រចាំខែមេសា** | **84,100,000** | **67,000,000** | **17,100,000** |

| | |
|---|---|
| ចំណូលសរុបពីល្បែងពាណិជ្ជកម្មអវិជ្ជមាន (ខាត) ពីខែមុន (មីនា) | (5,000,000) រៀល |
| ចំណូលសរុបពីល្បែងភ្នាល់ប្រចាំខែ | 17,100,000 រៀល |
| ចំណូលសរុបពីល្បែងភ្នាល់ | **12,100,000 រៀល** |

**១. អាករលើតម្លៃបន្ថែម អត្រា ១០% ÷**

មូលដ្ឋានគិតអាករលើតម្លៃបន្ថែម = 12,100,000 / 1.1 = 11,000,000 រៀល

ដូចនេះអាករលើតម្លៃបន្ថែម = 11,000,000 * 10% = 1,100,000 រៀល

**២. ប្រាក់រំដោះពន្ធលើប្រាក់ចំណូល អត្រា ១% ÷**

មូលដ្ឋានគិតប្រាក់រំដោះ = 12,100,000 - 1,100,000 = 11,000,000 រៀល

ដូចនេះប្រាក់រំដោះពន្ធលើប្រាក់ចំណូល = 11,000,000 * 1% = 110,000 រៀល

**ឧទាហរណ៍ទី១៤ ករណីក្រុមហ៊ុនមានចំណូលសរុបពីល្បែងកាស៊ីណូផង និងពីល្បែងផ្សងសំណាងផង÷**

នៅក្នុងខែឧសភា ក្រុមហ៊ុន ***គឃង*** មានចំណូលសរុបពីល្បែងកាស៊ីណូ (ទាំងតុល្បែង និងម៉ាស៊ីនល្បែង) ប្រចាំខែសរុបចំនួន 625,000,000 រៀល និងមានចំណូលសរុបពីការលក់សន្លឹកឆ្នោត (ក្រោយបានទូទាត់ប្រាក់ឈ្នះជូនអតិថិជន) ប្រចាំខែសរុបចំនួន 244,000,000 រៀល ។

ដូច្នេះ ក្រុមហ៊ុន ***គឃង*** ត្រូវធ្វើការគណនាប្រាក់ពន្ធ-អាករ ចំពោះចំណូលពីល្បែងពាណិជ្ជកម្មសម្រាប់ខែឧសភា ដូចខាងក្រោម÷

| | |
|---|---|
| ចំណូលសរុបពីល្បែងកាស៊ីណូ | 625,000,000 រៀល |
| ចំណូលសរុបពីល្បែងផ្សងសំណាង | 244,000,000 រៀល |
| ចំណូលសរុបពីល្បែងពាណិជ្ជកម្ម | **869,000,000 រៀល** |

**១. អាករលើតម្លៃបន្ថែម អត្រា ១០%÷**

មូលដ្ឋានគិតអាករលើតម្លៃបន្ថែម = 869,000,000 / 1.1 = 790,000,000 រៀល

ដូចនេះអាករលើតម្លៃបន្ថែម = 790,000,000 * 10% = **79,000,000 រៀល**

**២. ប្រាក់រំដោះពន្ធលើប្រាក់ចំណូល អត្រា ១%÷**

មូលដ្ឋានគិតពន្ធ = 869,000,000 - 79,000,000 = 790,000,000 រៀល

ដូចនេះប្រាក់រំដោះពន្ធលើប្រាក់ចំណូល = 790,000,000 * 1% = **7,900,000 រៀល**

**ឧទាហរណ៍ទី១៥ ករណីក្រុមហ៊ុនមានចំណូលពីល្បែងផ្សងសំណាង (អវិជ្ជមាន) ÷**

នៅក្នុងខែមិថុនា ក្រុមហ៊ុន ***គឃង*** មានចំណូលសរុបពីល្បែងកាស៊ីណូ (ទាំងតុល្បែង និងម៉ាស៊ីនល្បែង) ប្រចាំខែសរុបចំនួន 795,000,000 រៀល និងមានចំណូលសរុបពីល្បែងផ្សងសំណាងអវិជ្ជមាន (ក្រោយពីទូទាត់ប្រាក់ឈ្នះជូនអតិថិជន) ប្រចាំខែសរុបចំនួន (80,000,000) រៀល ។

ដូច្នេះ ក្រុមហ៊ុន ***គឃង*** ត្រូវធ្វើការគណនាប្រាក់ពន្ធ-អាករ ចំពោះចំណូលពីល្បែងពាណិជ្ជកម្មសម្រាប់ខែមិថុនា ដូចខាងក្រោម÷

| | |
|---|---|
| ចំណូលសរុបពីល្បែងកាស៊ីណូ | 795,000,000 រៀល |
| ចំណូលសរុបពីល្បែងផ្សងសំណាង | (80,000,000) រៀល |
| ចំណូលសរុបពីល្បែងពាណិជ្ជកម្ម | **715,000,000 រៀល** |

**១. អាករលើតម្លៃបន្ថែម អត្រា ១០%÷**

មូលដ្ឋានគិតអាករលើតម្លៃបន្ថែម = 715,000,000 / 1.1 = 650,000,000 រៀល

ដូចនេះអាករលើតម្លៃបន្ថែម = 650,000,000 * 10% = **65,000,000 រៀល**

**២. ប្រាក់រំដោះពន្ធលើប្រាក់ចំណូល អត្រា ១%÷**

មូលដ្ឋានគិតពន្ធ = 715,000,000 - 65,000,000 = 650,000,000 រៀល

ដូចនេះប្រាក់រំដោះពន្ធលើប្រាក់ចំណូល = 650,000,000 * 1% = **6,500,000 រៀល**

**ឧទាហរណ៍ទី១៦ ករណីឈ្នះរង្វាន់ជាវត្ថុ ÷**

នៅក្នុងខែកក្កដា ក្រុមហ៊ុន Lottery ***កខគ*** ទទួលបានចំណូលពីការលក់ឆ្នោតផ្សងសំណាងចំនួន 269,200,000 រៀល និងបានទូទាត់ប្រាក់ឈ្នះចំនួន 27,200,000 រៀល ព្រមទាំងរង្វាន់ជារថយន្ត ០១គ្រឿងជូនអតិថិជន។ រថយន្តដែលបានផ្តល់ជារង្វាន់នេះ ក្រុមហ៊ុនបានទិញក្នុងតម្លៃ 220,000,000 រៀល (រួមបញ្ចូលទាំងអាករលើតម្លៃបន្ថែម)។

ដូច្នេះ ក្រុមហ៊ុន Lottery *កខគ* ត្រូវធ្វើការគណនាប្រាក់ពន្ធ-អាករ ចំពោះចំណូលពីល្បែងពាណិជ្ជកម្មសម្រាប់ខែកក្កដា ដូចខាងក្រោម÷

| | |
|---|---|
| ចំណូលសរុបពីល្បែងផ្សងសំណាង | 269,200,000 រៀល |
| ប្រាក់ឈ្នះបានទូទាត់ | (27,200,000) រៀល |
| ចំណូលសរុបពីល្បែងពាណិជ្ជកម្ម | **242,000,000 រៀល** |

**១. អាករលើតម្លៃបន្ថែម អត្រា ១០%÷**

មូលដ្ឋានគិតអាករលើតម្លៃបន្ថែម = 242,000,000 / 1.1 = 220,000,000 រៀល

ដូចនេះអាករលើតម្លៃបន្ថែម = 220,000,000 * 10% = **22,000,000 រៀល**

** សម្រាប់រង្វាន់ជារថយន្តមួយគ្រឿងដែលក្រុមហ៊ុនបានទិញក្នុងតម្លៃ 220លានរៀល (រួមបញ្ចូលទាំងអាករលើតម្លៃបន្ថែម) ក្រុមហ៊ុន Lottery កខគ អាចស្នើសុំឥណទានអាករលើធាតុចូលសម្រាប់ការទិញរង្វាន់រថយន្តនេះបានចំនួន 20លានរៀល។*

**២. ប្រាក់រំដោះពន្ធលើប្រាក់ចំណូល អត្រា ១%÷**

មូលដ្ឋានគិតប្រាក់រំដោះ = 242,000,000 - 22,000,000 = 220,000,000 រៀល

ដូចនេះប្រាក់រំដោះពន្ធលើប្រាក់ចំណូល = 220,000,000 * 1% = **2,200,000 រៀល**

ឧបសម្ព័ន្ធទី៣ នៃប្រកាសលេខ [illegible] ចុះថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ [illegible]

## តារាងគណនាចំណូលសរុបពីល្បែងពាណិជ្ជកម្មប្រចាំខែ

## TABLE OF MONTHLY GGR CALCULATION FOR COMMERCIAL GAMBLING ACTIVITIES

ប្រចាំខែ For the Month of | M | M | ឆ្នាំ Year | Y | Y | Y | Y |

| | | |
|---|---|---|
| ចំណូលសរុបពីល្បែងពាណិជ្ជកម្មអវិជ្ជមាន (ខាត) ពីខែមុន (ប្រសិនបើមាន)<br>GGR Negative (loss) from Last Month (if any) | 01 | - |
| ចំណូលសរុបពីល្បែងកាស៊ីណូ ក្នុងខែ (តារាងទី១ក និងតារាងទី១ខ នៃឧបសម្ព័ន្ធនេះ)<br>GGR from casino for the Month (Table 1a and Table 1b of this annex) | 02 | 750,200,000 |
| ចំណូលសរុបពីល្បែងផ្សងសំណាង ក្នុងខែ (តារាងទី២ នៃឧបសម្ព័ន្ធនេះ)<br>GGR from raffles or lotteries for the Month (Table 2 of this annex) | 03 | 18,150,000 |
| ចំណូលសរុបពីល្បែងពាណិជ្ជកម្មដទៃទៀត ក្នុងខែ (តារាងទី៣ នៃឧបសម្ព័ន្ធនេះ)<br>GGR from other gambling activities for the Month (Table 3 of this annex) | 04 | 38,000,000 |
| ចំណូលសរុបពីល្បែងពាណិជ្ជកម្ម (រួមអតប) = ប្រអប់លេខ **(01+02+03+04) ប្រសិនបើ**អវិជ្ជមានត្រូវបំពេញ **0**<br>GGR (Inclusive of VAT) (if box (01+02+03+04) > 0 | 05 | 806,350,000 |
| ចំណូលសរុបពីល្បែងពាណិជ្ជកម្មអវិជ្ជមាន (ខាត) សម្រាប់យោងទៅខែបន្ទាប់ = ប្រអប់លេខ **(01+02+03+04)** ប្រសិនបើអវិជ្ជមាន<br>GGR Negative (loss) carry forward (if box (01+02+03+04) < 0 | 06 | - |

*តួលេខក្នុងប្រអប់លេខ (05) សហគ្រាសត្រូវបញ្ចូលជាចំណូលសរុបពីល្បែងពាណិជ្ជកម្មក្នុងបញ្ជីលក់នៃលិខិតប្រកាសពន្ធប្រចាំខែ

**តួលេខក្នុងប្រអប់លេខ (06) សហគ្រាសត្រូវយោងទៅបំពេញក្នុងប្រអប់លេខ(01) នៃឧបសម្ព័ន្ធនេះ នៅខែបន្ទាប់

## តារាងទី១ក÷ ប្រតិបត្តិការចំណូលសរុបប្រចាំថ្ងៃពីតុល្បែង ក្នុងខែ.... ឆ្នាំ២០...

Table 1a: Daily Gross Gaming Revenue Records From Table for Month .... Year ....

| ល.រ<br>No. | ថ្ងៃខែឆ្នាំ<br>Date | ឯកសារយោង<br>Reference Voucher | សារពើភ័ណ្ឌតុចុងគ្រា<br>Ending Inventory | ឥណទាន<br>Credit | ទម្លាក់<br>Drop | សារពើភ័ណ្ឌតុដើមគ្រា<br>Beginning Inventory | ហ្វ៊ិល<br>Fill | ចំណូលសរុបពីល្បែងកាស៊ីណូ ឈ្នះ/(ចាញ់)<br>Gross Gaming Revenue Win/(Lose) |
|---|---|---|---|---|---|---|---|---|
| | | | A | B | C | D | E | F = (A+B+C-D-E) |
| 1 | 01-02-2022 | V200 | 588,000,000 | 60,000,000 | 52,000,000 | 480,000,000 | 100,000,000 | 120,000,000 |
| 2 | 02-02-2022 | V201 | 550,000,000 | 185,000,000 | 183,954,000 | 588,000,000 | 80,954,000 | 250,000,000 |
| 3 | 03-02-2022 | V202 | 700,000,000 | 120,000,000 | 8,865,000 | 550,000,000 | 302,865,000 | (24,000,000) |
| .... | ........ | ........ | ........ | ........ | ........ | ........ | ........ | ........ |
| .... | ........ | ........ | ........ | ........ | ........ | ........ | ........ | ........ |
| .... | ........ | ........ | ........ | ........ | ........ | ........ | ........ | ........ |
| 27 | 27-02-2022 | V227 | 635,000,000 | 185,000,000 | 182,993,000 | 600,000,000 | 252,993,000 | 150,000,000 |
| 28 | 28-02-2022 | V228 | 600,000,000 | 192,000,000 | 57,765,000 | 635,000,000 | 250,765,000 | (36,000,000) |
| **សរុបប្រចាំខែ** | | | **3,073,000,000** | **742,000,000** | **485,577,000** | **2,853,000,000** | **987,577,000** | **460,000,000** |

សំគាល់÷ តួលេខប្រចាំថ្ងៃក្នុងជួរដេកនៃតារាងនេះ ជាតួលេខប្រាក់រៀលសរុបគ្រប់តុល្បែងទាំងអស់ប្រចាំថ្ងៃ ដូចឧទាហរណ៍ទី៣ ក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសលេខ .........

## តារាងទី១ខ៖ តារាងប្រតិបត្តិការចំណូលសរុបប្រចាំថ្ងៃពីម៉ាស៊ីនល្បែង ក្នុងខែ.... ឆ្នាំ២០...

Table 1b: Daily Gross Gaming Revenue Records From Slot Machine for Month .... Year ....

| ល.រ<br>No. | ថ្ងៃខែឆ្នាំ<br>Date | ឯកសារយោង<br>Reference Voucher | ទម្លាក់<br>Drop | ការកាត់បន្ថយ<br>Deduction and timing issues | ចំណូលសរុបពីល្បែងកាស៊ីណូ ឈ្នះ/(ចាញ់)<br>Gross Gaming Revenue Win/(Lose) |
|---|---|---|---|---|---|
| | | | A | B | C = (A - B) |
| 1 | 01-02-2022 | VM200 | 73,640,000 | 13,640,000 | 60,000,000 |
| 2 | 02-02-2022 | VM201 | (126,500,000) | (236,500,000) | 110,000,000 |
| 3 | 03-02-2022 | VM202 | 154,000,000 | 162,000,000 | (8,000,000) |
| .... | ........ | ........ | ........ | ........ | ........ |
| .... | ........ | ........ | ........ | ........ | ........ |
| .... | ........ | ........ | ........ | ........ | ........ |
| 27 | 27-02-2022 | VM227 | 218,700,000 | 98,500,000 | 120,200,000 |
| 28 | 28-02-2022 | VM228 | 17,200,000 | 9,200,000 | 8,000,000 |
| **សរុបប្រចាំខែ** | | | **335,900,000** | **45,700,000** | **290,200,000** |

**សំគាល់៖** តួលេខប្រចាំថ្ងៃក្នុងជួរដេកនៃតារាងនេះ ជាតួលេខប្រាក់រៀលសរុបគ្រប់ម៉ាស៊ីនល្បែងទាំងអស់ប្រចាំថ្ងៃ ដូចឧទាហរណ៍ទី៦ ក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសលេខ .........

## តារាងទី២÷ តារាងប្រតិបត្តិការចំណូលសរុបប្រចាំថ្ងៃពីល្បែងផ្សងសំណាង ក្នុងខែ.... ឆ្នាំ២០...

Table 2: Daily Gross Gaming Revenue Records from Raffles/Lotteries for Month .... Year ....

| ល.រ<br>No. | ថ្ងៃខែឆ្នាំ<br>Date | ឯកសារយោង<br>Reference Voucher | ប្រាក់ចាក់ភ្នាល់ទទួលបានពីការផ្សងសំណាងសរុប<br>Total Wager | ប្រាក់ទូទាត់ឱ្យអ្នកឈ្នះការផ្សងសំណាង<br>Winning Paid-out | ចំណូលសរុបពីល្បែងផ្សងសំណាង ឈ្នះ/(ចាញ់)<br>Gross Gaming Revenue Win/(Lose) |
|---|---|---|---|---|---|
| | | | A | B | C = A-B |
| 1 | 01-02-2022 | VL201 | 10,000,000 | 45,000,000 | (35,000,000) |
| 2 | 02-02-2022 | VL202 | 28,000,000 | - | 28,000,000 |
| 3 | 03-02-2022 | VL203 | 17,000,000 | - | 17,000,000 |
| .... | ........ | ........ | ........ | ........ | ........ |
| 15 | 15-02-2022 | VL215 | 18,000,000 | 45,000,000 | (27,000,000) |
| .... | ........ | ........ | ........ | ........ | ........ |
| 27 | 27-02-2022 | VL227 | 18,000,000 | - | 18,000,000 |
| 28 | 28-02-2022 | VL228 | 17,150,000 | - | 17,150,000 |
| **សរុបប្រចាំខែ** | | | **108,150,000** | **90,000,000** | **18,150,000** |

## តារាងទី៣៖ តារាងប្រតិបត្តិការចំណូលសរុបប្រចាំថ្ងៃពីល្បែងពាណិជ្ជកម្មដទៃទៀត ក្នុងខែ.... ឆ្នាំ២០...

Table 3: Daily Gross Gaming Revenue Records from other Gambling Activities for Month .... Year ....

| ល.រ<br>No. | ថ្ងៃខែឆ្នាំ<br>Date | ឯកសារយោង<br>Reference Voucher | ចំណូលដុលទទួលបានពីល្បែងពាណិជ្ជកម្មសរុប<br>Gross Revenue | ប្រាក់ទូទាត់ឱ្យអ្នកឈ្នះពីល្បែងពាណិជ្ជកម្ម<br>Winning Paid-out | ចំណូលសរុបពីល្បែងពាណិជ្ជកម្ម ឈ្នះ/(ចាញ់)<br>Gross Gaming Revenue Win/(Lose) |
|---|---|---|---|---|---|
| | | | A | B | C = A-B |
| 1 | 01-02-2022 | V301 | 30,000,000 | 8,000,000 | 22,000,000 |
| 2 | 02-02-2022 | V302 | 25,000,000 | 7,000,000 | 18,000,000 |
| .... | ........ | ........ | ........ | ........ | ........ |
| .... | ........ | ........ | ........ | ........ | ........ |
| .... | ........ | ........ | ........ | ........ | ........ |
| .... | ........ | ........ | ........ | ........ | ........ |
| 27 | 01-02-2022 | V327 | 45,000,000 | 28,000,000 | 17,000,000 |
| 28 | 02-02-2022 | V328 | 35,000,000 | 37,000,000 | (2,000,000) |
| **សរុបប្រចាំខែ** | | | **90,000,000** | **52,000,000** | **38,000,000** |